# មិនយកខ្មែរណាជាសត្រូវ ?

ជា ពាក្យស្លោក នយោបាយ ចង់ បង្ហាញ គតិបណ្ឌិត ជា អ្នក ផ្សះផ្សាជាតិ ក្នុង បរិបទ នៃ ទំនាស់ ឃោរឃៅ រវាង ដៃគូនយោបាយ។ ដូច្នេះ ន័យ នៃ ប្រយោគនេះ វា មាន អត្ថរស់ នៅក្នុង តម្លៃ គំនិត សន្តិភាពនិយម អកម្ម។ អ្វី ដែល ជា ជម្លោះ គ្រប់ រូបភាព ជា អវិជ្ជមាន ព្រោះ ជម្លោះ វា ផ្ទុយ នឹង សន្តិភាព។ ប៉ុន្តែ សន្តិភាព សកម្ម វា ជា សហវិជ្ជមាន នៃ ដៃគូ នៅក្នុង ជម្លោះ តាម សន្តិវិធី។ ជា ទូទៅ នៅក្នុង ពិភពលោកសព្វថ្ងៃ មនុស្ស មិន ទុកគ្នា ជា សត្រូវនោះឡើយ ព្រោះ មនុស្សលោក រស់ នៅក្នុង កំពស់ សីលធម៌ ពិភពលោក ខ្ពង់ខ្ពស់ និង មាន ច្បាប់ សាកល សំរាប់ ធានា សេរីភាព របស់ មនុស្សម្នាក់ៗ ដែល ហៅ ថា ច្បាប់ សិទ្ធិមនុស្ស។ ដូច្នេះ ពោលអះអាង ថា មិនយក ខ្មែរ ណា ជា សត្រូវ វា គ្រាន់តែ ជា ការអះអាង អ៊ីកអធឹក គ្មានអ្វី ជា គោលការណ៍ ដើម្បី ធ្វើឱ្យឃើញត្រូវ នឹង គោលបំណង ដែល ចង់ បាន គឺ សង្គ្រោះជាតិខ្មែរ ព្រោះ នៅក្នុង បរិបទ នៃ សង្គ្រោះ ជាតិ វា ច្បាស់ ជា មាន សត្រូវជាតិ ឬ វត្ថុអ្វី ដែល នឹងអាច បំផ្លាញជាតិ។ បើ ខ្មែរ រស់ នៅក្នុង សង្គម មាន កំពស់ សីលធម៌ ខ្ពង់ខ្ពស់ និង មាន ច្បាប់ សំរាប់ ធានា សេរីភាព របស់ពលរដ្ឋ ម្នាក់ៗ, ដូច្នេះ ជា ប្រត្យក្សភាព (évidence) វា គ្មាន ខ្មែរណា ជា សត្រូវ នឹង ខ្មែរដទៃ នោះឡើយ។ មួយវិញទៀត ប្រើ ពាក្យ « សត្រូវ » វា

# មិនយកខ្មែរណាជាសត្រូវ ?

បង្ហាញ ថា មាន ជម្លោះ ហិង្សា នៅ ចំពោះមុខ សត្រូវ ហិង្សា ហើយ យក ពាក្យ «ខ្មែរ» ដើម្បី អះអាង ថា សត្រូវនោះ ពុំមែន ជា សត្រូវ ព្រោះ ជា ខ្មែរ វា គ្រាន់ តែប្រើ របៀប រោគ វិទ្យា (syllogisme) : «ខ្មែរ និង ខ្មែរ ពុំជា សត្រូវ នឹងគ្នា, ខ្ញុំ ជា ខ្មែរ ដូច្នេះ គ្មាន ខ្មែរណា ជា សត្រូវ នឹងខ្ញុំ»។ ជា ការពិចារណា នៃ ទស្សនៈវិជ្ជា លើ ទ្រឹស្តី ធម្មជាតិ ឬ ច្បាប់ ធម្មជាតិ។ គំនិត ជាទូទៅ គឺ ឈរ លើ ជំនឿស៊ប់ ដែល ទុក សំណុំ នៃ ច្បាប់ ធម្មជាតិ ដែល មិនប្រែប្រួល នៅក្នុង ពេលវេលា និង ទីលំហ ជា ច្បាប់ ពិសាល ជាង ច្បាប់ ដែល អាជ្ញាធរ ទទួល អំណាចមួយ បង្កើត ឡើង សំរាប់ រៀបចំ សង្គម ហៅ ថា ច្បាប់ វិជ្ជមាន (droit positif)។ ដូច្នេះ ច្បាប់ វិជ្ជមាននេះ ត្រូវតែ នៅក្រោម អំណាច ច្បាប់ ធម្មជាតិ។ ជាការពិត ការអះអាង ថា «មិនយកខ្មែរណា ជាសត្រូវ» គឺ ទុក ជា ច្បាប់ ធម្មជាតិ ឬ ជំនឿស៊ប់ មាន វិសាលភាព ជាង ច្បាប់ វិជ្ជមាន នោះឯង។ ប៉ុន្តែ នៅ ស្រុកខ្មែរ ច្បាប់ វិជ្ជមាន គឺ ជា ច្បាប់ របស់ អំណាចផ្តាច់ការ ដែល គេ បង្កើត ឡើង សំរាប់ ការពារ ផលប្រយោជន៍ អំណាចផ្តាច់ការ។ នៅត្រង់ ចំណុចនេះឯង ដែល វា មាន ភាពផ្ទុយគ្នាទាំងស្រុង រវាង ជំនឿ ស៊ប់ របស់ គឹម សុខា នឹង ការទទួលស្គាល់ ច្បាប់ នៃ អំណាចផ្តាច់ការ ព្រោះ តែ គាត់ រស់ នៅក្រោម ដំបូល នៃ ព្រះរាជាណាចក្រ កម្ពុជា ដែល រស់ នៅក្រោម ដំបូល នៃ ច្បាប់ របស់ របប ផ្តាច់ ការ ច្បាស់លាស់ ដែល គឹម សុខា ខ្លួនឯង ជា ជនរងគ្រោះផ្ទាល់។ ដូច្នេះ ការអះអាងពីរ ផ្ទុយគ្នានោះ វា បង្កើត ដំបន់ ស្រមោល

នៃសម្មានភាព (sincérité) របស់ កឹម សុខា ជា អ្នកតស៊ូ នយោបាយ ជើងចាស់ ការពារ យុត្តិធម៌ និង សិទ្ធិមនុស្ស ថា តើអ្វីពិតទៅ ជា គតិបណ្ឌិត របស់គាត់។

មែនពិត កឹម សុខា គាត់ គ្មាន ជំរើសអ្វី ក្រៅពី ប្រតិបាទតាំច្បាប់ នៃ អំណាចផ្តាច់ការ ដើម្បី រស់នៅក្រៅ ពន្ធនាគារ និង ជាមួយគ្រួសារ។ ការណ៏នេះ ជា ទន្ទ្បីករណ៍[1] សមហេតុផល ព្រោះ កឹម សុខា ជា មនុស្សលោក, ជា ធម្មតា រមែង ខ្លាចទុក្ខ ព្រោះ គុក ដែល គាត់ ធ្លាប់ស្គាល់ រស់ជាតិ ពីរដងរួចមកហើយ វា ពិត ជា ទុក្ខ មិនអាចទ្រាំបាន សំរាប់គាត់ ទាំង ផ្លូវកាយ និង ចិត្ត។ តែ គុកនោះដែរ ទោះបី គាត់ចង់ ឬ មិនចង់ ក៏ វា ជា មូលធន នយោបាយ សំរាប់ គាត់ ក្នុង ឋានៈ ជា ជនរងគ្រោះ នៃ របប ផ្តាច់ការ លើ ឆាក អន្តរជាតិ និង ជាតិ។

លើ ឆាក ជាតិ « ការអះអាង ថា មិនយក ខ្មែរណា ជា សត្រូវ » វា មិនឆ្លើយថំនឹង គោលដៅ នយោបាយ ដែល គាត់ កំណត់ គឺ « សង្គ្រោះជាតិ » ព្រោះ ជាតិ វា មាន សត្រូវពិតប្រាកដណាស់ ជា ភាវរូបផង និង មនោគមវិជ្ជាផង គឺ ខ្មែរ មួយក្រុម ជា ជនផ្តាច់ការ ជា ឃាតករផង តែងតាំង ជា ប្រព័ន្ធ នៃ អំណាចផ្តាច់ការ ឃោរឃៅ ធ្វើ សកម្មភាព ប្រឆាំង ជាក់ស្តែងនឹង ផលប្រយោជន៏ជាតិ។ អំពើនេះឯង ដែលជា ភារៈអាស្រ័យហេតុ (raison d’être) នៃ អត្ថភាព ពេញសិទ្ធិ នៃ គណបក្សសង្គ្រោះជាតិ គឺ

---

[1] ទន្ទ្បីករណ៍ : សេចក្តីសំអាង។

# មិនយកខ្មែរណាជាសត្រូវ ?

បង្កើតឡើង សំរាប់ ប្រឆាំងនឹង អំណាចផ្តាច់ការ។ អត្តភាព ពេញសិទ្ធិ នោះឯង ដែល នាំឱ្យ គណបក្ស សង្គ្រោះជាតិ មាន ជ័យជំនះ ជាក់ស្តែង នៅឆ្នាំ ២០១៣ នៅលើ តម្លៃ ស្វាហាប់ នៃ ពាក្យស្លោកសឹក «ដូរ ឬ មិនដូរ!» និង «ហ៊ុន សែន អើយ ចុះចេញទៅ!»។ តែ ក្រោយមក ចាញ់សម្លុត ពួក ជនផ្តាច់ការ ក៏នាំគ្នា ដូរ ឧត្តមគតិខ្លួនឯង ទៅវិញ នាំគ្នា ចូលធ្វើ សហការ ជាមួយ ពួក ជនផ្តាច់ការ។ សួរថា តើ សព្វថ្ងៃ វាបានអ្វីខ្លះ សំរាប់ ផលប្រយោជន៍ជាតិ ? សព្វថ្ងៃ កឹម សុខា ជា និមិត្តរូប នៃ «ភាពទទេ នៃ នយោបាយ»។ ប្រជាពលរដ្ឋខ្មែរ គាត់ ព្រងើយកណ្តើយ នឹង រឿងកាត់ក្តី របស់គាត់ នៅ តុលាការ ដែល រិតតែបញ្ជាក់ បន្ថែម លើ ភាពទទេ នៃ នយោបាយ រហូត អាចទុកបាន ជា គ្មាន ព្រឹត្តិការណ៍ លើ ឆាកជាតិ។ មួយវិញទៀត ពួក អ្នកគាំទ្រ គាត់ តែងតែ ផ្សាយ សារ ថា កឹម សុខា ជា នយ:ជន[2] មិន ស្រឡាញ់ អំណាច ដែល កាត់តែ បន្ថយ រូបភាពគាត់ ជា អ្នកតស៊ូ នយោបាយ ប្រឆាំងនឹង របប ផ្តាច់ការ ព្រោះ វា មិនដែល មាន នយ:ជនណា មិន ស្រឡាញ់ អំណាច នោះឡើយ ព្រោះ អំណាចនោះឯង វា ជា មធ្យោបាយ នៃ នយោបាយ សំរាប់ ធ្វើ សមិទ្ធិកម្ម នៃ គោលដៅ នយោបាយ។

លើ ឆាក អន្តរជាតិ តួនាទី របស់ កឹម សុខា សព្វថ្ងៃ មាន ទ្វេ : ទី ១ គឺ ជា ឧណ្ហមាត្រ (thermomètre) របស់ សហគមន៍ អន្តរជាតិ សំរាប់

[2] នយ:ជន : អ្នកនយោបាយសកម្ម។

# មិនយកខ្មែរណាជាសត្រូវ ?

ស្ទង់កំដៅ នៃ របប ផ្ដាច់ការ នៅ ស្រុកខ្មែរ។ បើ វា ឡើងក្ដៅ គេ ធ្វើសម្ពាធ តាមផ្លូវទូត ទៅលើ របបដឹកនាំ, បើ វា ចុះក្ដៅ គេ បន្ត តាមពិនិត្រមើល។ តួនាទីនេះ ជា តួនាទី អកម្ម ដែល កឹម សុខា ជ្រើសរើស ដោយ ខ្លួនឯង នៅក្នុង ទស្សនៈ របស់គាត់ : « រស់នៅ ក្រោម ដំបូល នៃ ព្រះរាជាណាចក្រកម្ពុជា »។ តួនាទី ទី ២ របស់ កឹម សុខា សំរាប់ សហគមន៍ អន្តរជាតិ គឺ វិធី ដោះស្រាយ បញ្ហា នយោបាយ នៅ ស្រុកខ្មែរ តាម មធ្យោបាយ នៃ ការផ្សះផ្សាជាតិ នៅក្នុង គោលការណ៍ នៃ លទ្ធិប្រជាធិបតេយ្យ។ ចំពោះ សហគមន៍ អន្តរជាតិ តួនាទី ទី២ វា អាស្រ័យ ទៅលើ កំដៅនយោបាយ នៃ របប ក្រុងភ្នំពេញ។ បើ វា ក្ដៅពេក វា នឹង ពុំអាច បង្កើត លក្ខខណ្ឌ គ្រប់គ្រាន់ សំរាប់ តួនាទី ទី២ របស់ កឹម សុខា នោះឡើយ ក៏ដូចគ្នា បើ កឹម សុខា គាត់ មាន នយោបាយ ត្រជាក់ពេក ជាមួយ របប ក្រុងភ្នំពេញ ផងដែរ។ ថ្មីៗនេះ ការចូលជួប បន្តៗគ្នា នៃ អគ្គរដ្ឋទូត នៃ ប្រទេស នៃ សហគមអឺរ៉ុប មួយចំនួន និង សហរដ្ឋអាមេរិក គឺ គេ ធ្វើ ក្នុង ការស្ទង់មើល កំដៅ នយោបាយ ទាំងសងខាង ព្រោះ ថ្ងៃ កំណត់ នៃ ការដកហូត នៃ ការអនុគ្រោះព័ន្ធ EBA វា កាត់តែ ជិតមកដល់។ ចំពោះ សហគមន៍ អន្តរជាតិ ការផ្សះផ្សាជាតិ មាន ប្រសិទ្ធភាព និង អាច គង់វង់បាន គឺ មិនស្ថិត នៅលើ ការសម្រុះសម្រួល រវាង កឹម សុខា នឹង ហ៊ុន សែន នោះឡើយ ព្រោះ វា មាន ការពិសោធ រួចមកហើយ។ ដូច្នេះ ចំពោះ សហគមន៍ អន្តរជាតិ ទស្សនៈ « មិនយក ខ្មែរណា ជា សត្រូវ » វា ពុំមែន

# មិនយកខ្មែរណាជាសត្រូវ ?

ជា រូបមន្ត នយោបាយ សំរាប់ ល្បង គេបាននោះឡើយ។ អ្វី ដែល គេ ចង់ បាន គឺ គេ ចង់ឃើញ កឹម សុខា មាន សេចក្តីប្តេជ្ញា គ្មាន ក្រហែង របស់ គាត់ ក្នុង ការតស៊ូ នយោបាយ ដើម្បី សង្គ្រោះជាតិខ្មែរ ជា បឋម គឺ សង្គ្រោះ លទ្ធិប្រជាធិបតេយ្យ នោះ ឯង មិនមែន កឹម សុខា រស់ ជា ជនរង្គ្រោះ រំអួយ និង ស្លឹក នោះឡើយ។ កឹម សុខា ជា អ្នកប្រយុទ្ធ ការពារ លទ្ធិប្រជាធិបតេយ្យ និង យុត្តិធម៌ ជា លក្ខខណ្ឌ ដែល គាត់ អាចនឹងមាន ធម្មានុរូប សំរាប់ ដើរតួនាទី ជា ប្រធាន នៃ គណបក្ស សង្គ្រោះជាតិ, ពុំនោះសោធ គឺ គាត់ យក ទស្សនៈ «មិនយកខ្មែរណាជាសត្រូវ» ជា ម្លប់ នៃ សុភមង្គលអាត្មា តែប៉ុណ្ណោះ។ ប៉ុន្តែ កឹម សុខា នៅតែ បន្ត យល់ច្រឡំ ថា គាត់ ធ្វើជា អ្នកបំរើ ជនផ្តាច់ការ ប្តូរនឹង សេចក្តីសុខ នឹងទទួលបាន សេចក្តីសុខ។ តែ ចំពោះ ជនផ្តាច់ការ វិញ គេ ទុក កឹម សុខា គ្រាន់តែ ជា អ្នកបំរើ ដែលជាឱកាស តែ ប៉ុណ្ណោះ ហើយ នៅពេលណា ដែល គេ លែងត្រូវការ គេ នឹង កំទិចចោល ជាពុំខាន៕